**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

**សភាព្រហ្មទណ្ឌ**
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៦៣
ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩
សាលដីកា
លេខ ៥៥ "II"
ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០
ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. ឯកឧត្តម [redacted] ជាប្រធាន
២. លោក [redacted] ជាចៅក្រម
៣. លោក [redacted] ជាចៅក្រម
៤. លោក [redacted] ជាចៅក្រម
៥. លោកស្រី [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្ដឹងសាទុក្ខលេខ ៧១ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ឌី, ឈ្មោះ [redacted] ប៊ុនឈឿន និងឈ្មោះ [redacted] សុយុន ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១៨ "ក្រ.VI.ច" ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ដែលមាន ៖

-បុគ្គលប្ដឹងសាទុក្ខ ៖

១.ឈ្មោះ [redacted] ចាន់ឌី ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិលេខ [redacted] ខេត្តកណ្ដាល មានទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន។

Scanned with CamScanner

២.ឈ្មោះ [redacted] ប៊ុនធឿន ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ជានីតិជន ទោសពីមុនគ្មាន។

៣.ឈ្មោះ [redacted] សុឃុន ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ [redacted] ខេត្តកណ្តាល មានទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ជានីតិជន ទោសពីមុនគ្មាន។

-ជាប់ចោទពីបទ បង្ករបួសដោយចេតនា (ទៅវិញទៅមក) ប្រព្រឹត្តនៅភូមិលេខ៣ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១០ នៅចំណុចសហគ្រាសអ៊ីហ្គាមេន ខូអិលធីឌី ស្ថិតនៅភូមិលេខ៣ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ឈ្មោះ [redacted] សុខេង និងឈ្មោះ [redacted] សំបូរ មានឈ្លោះប្រកែកគ្នាជាមួយឈ្មោះ [redacted] ខាន់ បន្ទាប់មកឈ្មោះ [redacted] សំបូរ ក៏វាយត្រូវឈ្មោះ [redacted] ខាន់ មួយដៃចំពីក្រោយ ឃើញដូចនោះឈ្មោះ [redacted] ណារ៉ុង ក៏ចូលទៅជួយ តែត្រូវក្រុមរបស់ឈ្មោះ [redacted] សុខេង ឈ្មោះ [redacted] សំបូរ ឈ្មោះ [redacted] ធន ឈ្មោះ [redacted] ចាន់ឌី ឈ្មោះ [redacted] ពៅ ឈ្មោះ [redacted] សុខជា ឈ្មោះ [redacted] កញ្ញា ឈ្មោះ [redacted] វុទ្ធី ឈ្មោះ [redacted] ប៊ុន ធឿន និងឈ្មោះ [redacted] សុឃុន បានព្រួតវាយគ្នាទៅលើឈ្មោះ [redacted] ខាន់ និងឈ្មោះ [redacted] ណារ៉ុង ហើយក៏មានការប្រតាយប្រតប់គ្នាទៅវិញទៅមក។ បន្ទាប់មកឈ្មោះ [redacted] សុវណ្ណឌី និងឈ្មោះ [redacted] យិន បានចូលទៅជួយក៏ត្រូវក្រុមរបស់ ឈ្មោះ [redacted] សុខខេង ឈ្មោះ [redacted] សំបូរ ឈ្មោះ [redacted] ធន ឈ្មោះ [redacted] ចាន់ឌី ឈ្មោះ [redacted] ពៅ ឈ្មោះ [redacted] សុខជា ឈ្មោះ [redacted] កញ្ញា ឈ្មោះ [redacted] វុទ្ធី ឈ្មោះ [redacted] ប៊ុនធឿន និងឈ្មោះ [redacted] សុឃុន ព្រួតគ្នាវាយផងដែរ បង្កឱ្យមានការវាយប្រតាមប្រតប់គ្នាពេញរោងចក្របណ្តាលឱ្យមានរបួសទាំងសងខាង។

សាលាដំបូងខេត្តកណ្តាល បានសម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ១០ "ណ" ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅនេះ ៖

១.ផ្តន្ទាទោស ៖

ក.ឈ្មោះ [redacted] សុខខេង ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ

ខ.ឈ្មោះ [redacted] សំបូរ ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ

គ.ឈ្មោះ [redacted] ធន ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ

ឃ.ឈ្មោះ [redacted] ចាន់ឌី ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ

ង.ឈ្មោះ [redacted] ពៅ ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ



Scanned with CamScanner

ច.ឈ្មោះ [redacted] សុខជា ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ

ឆ.ឈ្មោះ [redacted] កញ្ញា ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ

ជ.ឈ្មោះ [redacted] វុទ្ធី ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ

ឈ.ឈ្មោះ [redacted] ប៊ុនឈឿន ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ

ញ.ឈ្មោះ [redacted] សុឃុន ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ

ដ.ឈ្មោះ [redacted] ខាន់ ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ

ឋ.ឈ្មោះ [redacted] យិន ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ

ឌ.ឈ្មោះ [redacted] ណារ៉ុង ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ

ឍ.ឈ្មោះ [redacted] សុវណ្ណឌី ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ ៦ (ប្រាំមួយ)ខែ ពីបទ បង្ករបួសស្នាមដោយចេតនា(ទៅវិញទៅមក) ប្រព្រឹត្តនៅ ភូមិលេខ៣ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ស្តីពីច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២.បង្គាប់ឱ្យ ៖

ក.ឈ្មោះ [redacted] សំបូរ

ខ.ឈ្មោះ [redacted] ធន

រួមគ្នាសងប្រាក់ថ្លៃព្យាបាលរបួស និងជម្ងឺចិត្ត ឱ្យឈ្មោះ [redacted] ខាន់ និងឈ្មោះ [redacted] ណារ៉ុង ជាប្រាក់ចំនួន ៣០០០$ (បីពាន់ដុល្លាអាមេរិក) ការទាមទារលើសពីនេះលើកចោល។

គ.ឈ្មោះ [redacted] ខាន់

ឃ.ឈ្មោះ [redacted] ណារ៉ុង

រួមគ្នាសងថ្លៃព្យាបាលរបួស និងជម្ងឺចិត្តឱ្យឈ្មោះ [redacted] សំបូរ ឈ្មោះ [redacted] ធន ជាប្រាក់ចំនួន ៣០០០$ (បីពាន់ដុល្លាអាមេរិក) ការទាមទារលើសពីនេះលើកចោល។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខគូភាគីបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

សាលក្រមព្រហ្មទណ្ឌនេះត្រូវបានឈ្មោះ [redacted] សំបូរ, [redacted] ពៅ, [redacted] វុទ្ធី, [redacted] កញ្ញា, [redacted] ចាន់ឌី, [redacted] ធន, [redacted] សុឃុន និង ឈ្មោះ [redacted] ប៊ុនឈឿន ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ១៧ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ១០ "ណ" ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣ របស់សាលាសាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

សាលាឧទ្ធរណ៍បានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ១៨ "ក្រ IV ច" ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

Scanned with CamScanner

១. ទទួលពាក្យបណ្ដឹងឧទ្ធរណ៍លេខ ១៧ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] សំបូរ, ឈ្មោះ [redacted] ពៅ, ឈ្មោះ [redacted] វុទ្ធី ឈ្មោះ [redacted] កញ្ញា ឈ្មោះ [redacted] ចាន់ឌី ឈ្មោះ [redacted] ធន ឈ្មោះ [redacted] សុឃុន និង ឈ្មោះ [redacted] ប៊ុនឈឿន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ និងគតិច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០ "ណ" ចុះថ្ងៃទី២៥ខែមីនា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តកណ្ដាល ទុកជាបានការដដែល។

សាលដីកានេះជំនុំជម្រះជាសាធារណៈថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ កំបាំងមុខជនជាប់ចោទ។

បើកផ្លូវប្ដឹងតវ៉ា ក្នុងកំណត់ច្បាប់ ។

សាលដីកានេះ ត្រូវបានជនជាប់ចោទឈ្មោះ [redacted] ចាន់ឌី, ឈ្មោះ [redacted] ប៊ុនឈឿន និងឈ្មោះ [redacted] សុឃុន ប្ដឹងសាទុក្ខ តាមបណ្ដឹងលេខ ៧១ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ ត្រង់ចំណុចនៃសេចក្ដីសម្រេច ទាំងមូល។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូល បានធ្វើសេចក្ដីសន្និដ្ឋានថា ការសម្រេចសេចក្ដីរបស់ សាលាឧទ្ធរណ៍ ដែលតម្កល់សាលក្រមព្រហ្មទណ្ឌ របស់សាលាដំបូងទុកជាបានការដដែល គឺមានមូលដ្ឋាន សំអាង ត្រឹមត្រូវតាមច្បាប់ ព្រោះថា៖ តាមចម្លើយរបស់ជនជាប់ចោទ ដែលជាភាគីទំនាស់ទាំងសងខាង ដែលឆ្លើយដោះសារ និងដោះបន្ទុកលើគ្នាទៅវិញទៅមក បង្ហាញឱ្យឃើញថា ជនជាប់ចោទពិតជាបាន ប្រព្រឹត្តអំពើបង្ករបួសស្នាមលើគ្នាទៅវិញទៅមក ដូចមានក្នុងសំអាងហេតុចំណុចទី១០ នៃសាលដីកា សាលាឧទ្ធរណ៍ស្រាប់។ ហេតុដូច្នេះ តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេច តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ ១៨ "ក្រ.VI.ច" ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ទុកជា បានការដដែល។

-ក្រឡាបញ្ជីបានអានសារណាការពាររបស់ឈ្មោះ [redacted] ចាន់ឌី, ឈ្មោះ [redacted] ប៊ុនឈឿន និងឈ្មោះ [redacted] សុឃុន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩ នាពេលសវនាការ។

## តុលាការកំពូល

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ។

Scanned with CamScanner

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៧១ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទ ឈ្មោះ [redacted] ចាន់ឌី, ឈ្មោះ [redacted] ប៊ុនឈឿន និងឈ្មោះ [redacted] សុយុន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧ មាត្រា ៤១៨ និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការដែលជនជាប់ចោទទាំង ៣ នាក់លើកឡើងថា "*នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១០ ពិត ជាមានករណីហិង្សាដោយចេតនា នៅក្នុងបរិវេណសហគ្រាស អ៊ី ហ្គាមែន ដែលបង្កឡើងដោយឈ្មោះ [redacted] ខាន់, [redacted] ណារ៉ុង, [redacted] សុវណ្ណឌី និងបក្ខពួក ពិតប្រាកដមែន។ ហើយករណីហិង្សានេះកើតឡើងរួចហើយ ទើបពួកខ្លួន ៣ នាក់បានទៅដល់កន្លែងកើតហេតុ និងបានជួយឃាត់សកម្មភាពហិង្សានេះ។ ប៉ុន្តែជារឿងមួយដែលគួរឱ្យសោកស្តាយនោះ ដោយក្នុងអំឡុងពេលនោះ បែរជាត្រូវក្រុមជនបង្កហិង្សាដោយចេតនាបានប្រើហិង្សាមកលើពួកខ្លួនបណ្តាលឱ្យ ពួកខ្លួនទទួលរងរបួសទៅវិញ។ ពួកខ្លួនមិនមែនជាអ្នកប្រព្រឹត្តទេ បែរជាតុលាការចោទប្រកាន់ពួកខ្លួនទៅវិញ*" នោះ គឺជាការមិនត្រឹមត្រូវទេ ពីព្រោះថា តាមកស្តុតាងនៅក្នុងសំណុំរឿងក្តីនេះ ជាពិសេសចម្លើយរបស់ជនជាប់ចោទ ទាំង ៣ នាក់ផ្ទាល់ ដែលបានបង្ហាញថា នៅខណៈពេលកើតហេតុ ជនជាប់ចោទទាំងបីរូបនេះពិតជាមានវត្តមាន និងបានចូលរួមប្រព្រឹត្តដោយផ្ទាល់នៅទីកន្លែងកើតហេតុ និងមិនមានកស្តុតាងណាផ្សេងណាដែលដោះបន្ទុកការចោទប្រកាន់លើពួកគាត់នោះទេ ក្រៅតែពីចម្លើយដោះសាររបស់ពួកខ្លួនថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះ។ ដូច្នេះតុលាការកំពូលឯកភាពទាំងផ្នែកសំអាងហេតុ ទាំងផ្នែកសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ភ្នំពេញ ក្នុងសាលដីកាព្រហ្មទណ្ឌលេខ ១៨ "ក្រ.VI.ច" ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ ។

៤-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៧១ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទ ឈ្មោះ [redacted] ចាន់ឌី , ឈ្មោះ [redacted] ប៊ុនឈឿន និងឈ្មោះ [redacted] សុយុន មិនមានមូលហេតុនៃបណ្តឹងសាទុក្ខសមស្របនឹងចំណុច ណាមួយ ឬច្រើននៃបទបញ្ញត្តិមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះឡើយ។

*៥-យល់ឃើញថា* សាលដីកាព្រហ្មទណ្ឌលេខ ១៨ "ក្រ.VI.ច" ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះត្រឹមត្រូវតាមច្បាប់ហើយ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១-បដិសេធបណ្តឹងសាទុក្ខលេខ ៧១ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ឌី, ឈ្មោះ [redacted] ប៊ុនឈឿន និងឈ្មោះ [redacted] សុយុន ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១៨ "ក្រ.VI.ច" ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល។

Scanned with CamScanner

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃសុក្រ ទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសនាសនាការ ជាសាធារណៈ នៅថ្ងៃសុក្រ ទី០៦ ខែមីនា ឆ្នាំ២០២០ ។/

Scanned with CamScanner